# គោលការណ៍ប្រតិបត្តិបែបកុមារមេត្រី

## *ករណីកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ*

គោលការណ៍ប្រតិបត្តិបែបកុមារមេត្រីមានន័យថានៅពេលដែលកុមារមកទាក់ទងជាមួយនគរបាល និងប្រព័ន្ធយុត្តិធម៌ ពួកគេគួរទទួលបានសេវាគាំទ្រសមរម្យ គ្រប់គ្រាន់ និងប្រកបដោយសុវត្ថិភាព។ ដូច្នេះ អ្នកពាក់ព័ន្ធត្រូវធានាថា៖

- ផ្តល់ទីកន្លែងដែលមានសុវត្ថិភាព
- ផ្តល់ភាពថ្លៃថ្នូរ
- គ្មានការរើសអើង
- គិតគូរឧត្តមប្រយោជន៍កុមារ
- អនុវត្តផ្អែកលើការគោរពសិទ្ធិកុមារ
- មានវត្តមានរបស់មន្ត្រីសុខុមាលភាពសង្គម និងអាណាព្យាបាល
- ផ្តល់ឯកជនភាព និងការរក្សាការសម្ងាត់
- ពិចារណា និងឆ្លើយតបសមស្របទៅនឹងតម្រូវការរបស់កុមារមានពិការភាព
- ពិចារណាអំពីយេនឌ័ររបស់មន្ត្រីនគរបាលដែលធ្វើការជាមួយកុមារ
- ឆ្លើយតបតាមតម្រូវការរបស់កុមារ និងគ្រួសារ
- ដាក់ដាច់ដោយឡែករវាងកុមារ និងជនសង្ស័យ
- ប្រើប្រាស់ភាសា ទៅតាមអាយុ និងកម្រិតយល់ដឹងរបស់កុមារ



ស្វែងយល់បន្ថែមស្តីពីគោលការណ៍ប្រតិបត្តិបែបកុមារមេត្រី នៅទីនេះ!

APLE

Terre des Hommes

# តើយើងធ្វើដូចម្ដេច ទើបដឹងថាមានការអនុវត្តបែបកុមារមេត្រី?

**អនុវត្តបែបកុមារមេត្រី- វិធីសាស្ត្រផ្ដោតលើកុមារ៖** នៅគ្រប់ករណីទាំងអស់ពាក់ព័ន្ធនឹងកុមាររងគ្រោះ ឬសាក្សី ចាំបាច់គួរអនុវត្តវិធានការ និងកិច្ចគាំពារនានា ដើម្បីការពារពួកគេពីគ្រោះថ្នាក់គ្រប់ប្រភេទ ឬភាពរងគ្រោះផ្សេងៗទៀត ដែលអាចកើតឡើងនៅពេលចូលរួមនៅក្នុងដំណើរការយុត្តិធម៌។

**ធ្វើការជាដៃគូដើម្បីធានាបាននូវវិធីសាស្ត្រពហុវិស័យប្រកបដោយប្រសិទ្ធភាព៖** ធ្វើការងាររួមគ្នាប្រកបដោយប្រសិទ្ធភាព និងសេចក្ដីគោរពដោយត្រូវទទួលខុសត្រូវ ចំពោះគ្នាទៅវិញទៅមក និងមានគណនេយ្យភាព។

**អនុវត្តវិធីសាស្ត្រផ្ដោតលើយេនឌ័រ និងបរិយាប័ន្ន៖** ឆ្លើយតបតាមតម្រូវការជាក់លាក់របស់ជនរងគ្រោះនៅគ្រប់ពេលវេលា និងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងប្រព្រឹត្តចំពោះពួកគេប្រកបដោយការគោរព ព្រមទាំងលើកកម្ពស់សេចក្ដីថ្លៃថ្នូរ។

**ផ្ដល់អាទិភាពដល់សុខុមាលភាព និងឧត្ដមប្រយោជន៍របស់កុមារ៖** ការសម្ភាសជាមួយកុមារ គួរតែរៀបចំឡើងនៅទីកន្លែងឯកជន មានសុកភាព មិនមានការរំខាននានា ( ឧ. ទូរសព្ទរោទិ៍ មនុស្សដើរកាត់ចុះឡើង ) និងមានសុវត្ថិភាពទាំងផ្លូវចិត្ត និងផ្លូវកាយសម្រាប់កុមារ។

ស្វែងយល់បន្ថែមស្ដីពីគោលការណ៍ប្រតិបត្តិបែបកុមារមេត្រី នៅទីនេះ!

APLE

Terre des Hommes

## តើកុមាររងគ្រោះគួរទទួលបានសេវាសមស្របអ្វីខ្លះ?

# ការផ្តល់សេវាសមស្របដល់កុមាររងគ្រោះ គឺលើសពីការរាយការណ៍...

សេវាសមស្របសម្រាប់កុមាររងគ្រោះ រួមមាន៖

- ការគាំទ្រផ្លូវចិត្ត និងថែទាំសុខភាព
- ជំនួយផ្នែកច្បាប់
- ព័ត៌មានពេញលេញ ពីនីតិវិធីនៃសំណុំរឿង
- ការសម្របសម្រួលដកហូតរូបភាពនិងសម្ភារៈរំលោភបំពានផ្លូវភេទ ចេញពីប្រព័ន្ធអនឡាញ
- ការបង្ការទប់ស្កាត់បទល្មើស
- ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ




APLE

Terre des Hommes

# ការលុបរូបភាព និងសម្ភារៈរំលោភបំពាន ផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ

“ ជារឿងរហូត

## ខ្ញុំសង្ឃឹមថា......

នឹងមិនមានរូបភាពរំលោភបំពាន
ផ្លូវភេទរបស់ខ្ញុំលើប្រព័ន្ធអនឡាញ។”



សូមរាយការណ៍ ប្រសិនបើអ្នកជួបប្រទះ
រូបភាព ឬសម្ភារៈរំលោភបំពាន
ផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ។

APLE

Terre des Hommes

# តើការដកហូតរូបភាពនិងសម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) ដំណើរការដោយរបៀបណា?

## ជំហានទី១៖ ការរាយការណ៍ (CSAM)

រាយការណ៍អំពីរូបភាព និងសម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) លើប្រព័ន្ធអនឡាញដែលសង្ស័យមកកាន់អង្គការសកម្មភាពដើម្បីកុមារ (APLE) តាមរយៈ www.aplecambodia.org ។

## ជំហានទី២៖ ដំណើរការវិភាគ

របាយការណ៍ត្រូវបានវិភាគដោយអ្នកជំនាញដែលមានការទទួលស្គាល់ ។

## ជំហានទី៣៖ ការបញ្ជូនលទ្ធផលវិភាគ និងរបាយការណ៍

ប្រសិនបើរកឃើញថាមានភាពខុសច្បាប់ របាយការណ៍និងត្រូវបញ្ជូនទៅភ្នាក់ងារអនុវត្តច្បាប់ ដើម្បីធ្វើការស៊ើបអង្កេត ។

## ជំហានទី៤៖ ការស្នើសុំការដកហូតនិងលុប CSAM

បញ្ជូនការស្នើសុំដកហូត និងលុបចេញ ទៅកាន់បណ្ដាញរាយការណ៍សកល ឬក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ។

## ជំហានទី៥៖ ការដកហូត និងលុប CSAM

CSAM ត្រូវបានដកហូត និងលុបចេញពីប្រព័ន្ធអនឡាញ ។

APLE

Terre des Hommes

ព័ត៌មានបន្ថែម៖